តុលាការដំបូងរបស់សហរដ្ឋអាមេរិក
សង្កាត់ ល្វីស៊ាណាខាងកើត
(UNITED STATES DISTRICT COURT
EASTERN DISTRICT OF LOUISIANA)

| | | |
|---|---|---|
| យោងលើ៖ ការធ្លាយប្រេងដោយសារការខួងយកប្រេង "តំបន់ទឹកជ្រៅ (Deepwater Horizon)" ឆ្នេរជាប់ឈូងសមុទ្រមិចស៊ីកូ ថ្ងៃទី20 ខែមេសា ឆ្នាំ 2010 | * * * * * | MDL No. 2179<br>ជំពូក៖ J<br>ចៅក្រម BARBIER |
| ឯកសារនេះអនុវត្តចំពោះ៖ រាល់រឿងក្តីទាំងអស់ (រួមទាំង 10-2771) | * * | ព្រះរាជអាជ្ញាឬចៅក្រមអម SHUSHAN |

## <u>សាលក្រម និងហេតុផល</u>

[យោងតាមបណ្តឹងលើការបង្កើតគណនី និងការតម្កល់ប្រាក់កក់ សម្រាប់ការចំណាយលើបណ្តឹងវិវាទ (ឯកសារលេខ 4507)]

គណៈកម្មការរបស់ដើមចោទ (“PSC”) បានដាក់ពាក្យបណ្តឹងលើការបង្កើតគណនី និង តម្កល់ប្រាក់ប្រដាប់ក្តី ដើម្បីស្វែងរកការបង្កើតផលប្រយោជន៍រួមមួយក្នុងការកាត់ប្រាក់មូលនិធិ ដោយយោងតាមឯកសារលេខ 4507។ យោងតាមសំណើររបស់គណៈកម្មការរបស់ដើមចោទ(PSC) ចុងចម្លើយដែលជាភាគីទាំងឡាយនៃបណ្តឹង(“MDL”) បានតម្រូវឲ្យមានការដោះស្រាយសំណុំរឿងរបស់ដើមចោទម្នាក់ៗ ដើម្បីកាត់ប្រាក់ និងបង់ទ្រព្យសម្បត្តិនៅក្នុងគណនីរួមពិសេសមួយក្នុងអំឡុងពេលដែលបានចុះបញ្ជីនៅតុលាការ នូវចំនួនសរុបដែលស្មើនឹង 6% នៃចំនួនទឹកប្រាក់ដែលត្រូវដោះស្រាយនៅក្នុងរឿងក្តីឯកជនរបស់ដើមចោទម្នាក់ៗ។ ក្នុងករណីដែលដើមចោទជារដ្ឋឬរដ្ឋាភិបាល ការកាត់ប្រាក់នូវទ្រព្យសម្បត្តិមានចំនួន4% នៃការដោះស្រាយវិវាទសរុប។ ដូចបានពន្យល់ដោយគណៈកម្មការរបស់ដើមចោទ (PSC) ក្នុងពាក្យបណ្តឹងសាលក្រមរបស់តុលាការនោះមិនគួរកំណត់ចំនួន ឬ ផ្តល់កម្រៃ ឬ ចំណាយរបស់ផលប្រយោជន៍រួមនានាឡើយ។ ប៉ុន្តែ គួរតែបង្កើតមូលនិធិធម្មតាមួយដែលបានមកពីកម្រៃរួម ប្រសិនបើអាច កម្រៃរួមនោះត្រូវបានបែងចែកនៅពេលក្រោយ។ មូលនិធិរួមនេះជានិច្ចកាលត្រូវបានប្រើប្រាស់ដោយតុលាការក្នុងបរិបទបណ្តឹងសមូហភាព (MDL) ដែលតុលាការតែងតាំងគណៈកម្មការរបស់ដើមចោទមួយ និងក្រុមប្រឹក្សាប្រធានរបស់ដើមចោទ ឬ

ក្រុមប្រឹក្សាសម្របសម្រួលរបស់ដើមចោទផ្សេងៗទៀត ដើម្បីរៀបចំ និងដឹកនាំរឿងក្តីតំណាងឲ្យដើមចោទរាប់ពាន់នាក់និងមេធាវីរាប់រយនាក់។ ដូច*ក្នុងរឿងក្តីគ្រោះមហន្តរាយក្រឡាប់យន្តហោះ (Air Crash Disaste) នៅ Florida Everglades ថ្ងៃទី29 ខែធ្នូ ឆ្នាំ 1972*, 549 F.2d 1006, 1017-18 (5th Cir. 1977); *In re Zyprexa Prods. Liab. Litig.*, 594 F.3d 113, 128-30 (2d Cir. 2010) (Kaplan, J., concurring); *In re Genetically Modified Rice Litig.*, No. 4:06-md-1811, 2010 WL 716190 at *4 & n.2 (E.D. Mo. Feb. 24, 2010); Fed. Judicial Ctr., *គោលការណ៍ណែនាំសម្រាប់បណ្តឹងវិវាទស្មុគស្មាញ ( Manual for Complex Litigation), ទីបួន* §§ 14.215, 20.312 (2004) ជាដើម។

អគ្គមេធាវីល្វីស៊ាណាបានបដិសេធការបង្កើតគណនីកាត់ប្រាក់មួយ ដែលកន្លងមកបានអនុវត្តនៅក្នុងរដ្ឋល្វីស៊ាណា។ រដ្ឋល្វីស៊ាណាជារដ្ឋមួយក្នុងចំណោមរដ្ឋពីរជាប់ឈូងសមុទ្រដែលមានពាក្យបណ្តឹងនានាក្នុងលក្ខណៈជាបណ្តឹងសមូហភាព (MDL) និងរដ្ឋអាឡាបាម៉ាផ្សេងទៀត។ ជាការសម្គាល់ អគ្គមេធាវីរបស់រដ្ឋអាឡាបាម៉ាបានព្រមព្រៀងជាមួយគណៈកម្មការរបស់ដើមចោទ ដើម្បីធ្វើការងារដោយសហការគ្នាចំពោះផលប្រយោជន៍រួមរបស់ពួកគាត់។ តាមមូលហេតុដ៏ច្រើននេះ តុលាការបានតែងតាំងអគ្គមេធាវីរដ្ឋអាឡាបាម៉ាឈ្មោះ Luther Strange ជាក្រុមប្រឹក្សាសម្របសម្រួលសម្រាប់រដ្ឋជាប់នឹងឈូងសមុទ្រ។ តុលាការបានភ្ជាប់ ទំនាក់ទំនងជាមួយគណៈកម្មការរបស់ដើមចោទ និង រដ្ឋអាឡាបាម៉ាជាយូរមកហើយដែលផលប្រយោជន៍របស់ពួកគាត់ត្រូវបានរៀបចំតាមលំដាប់លំដោយ ដើម្បីតតាំងនឹងចុងចម្លើយនៅក្នុងបណ្តឹងសមូហភាពដ៏ស្មុកស្មាញនេះ។ ជាងនេះទៀត ការសហប្រតិបត្តិការ ឬ គោលបំណងធ្វើការងារសហការគ្នាល្អ រដ្ឋល្វីស៊ាណាតែងតែបានជួបឧបសគ្គនិងបរាជ័យក្នុងដំណើការរឿងក្តីតាមរយៈក្រុមប្រឹក្សាឯកជនដែលមានកន្លងមក។

ថ្មីៗនេះ បន្ទាប់ពីមានភាពច្បាស់លាស់ថារដ្ឋល្វីស៊ាណាមិនអាចប្រតិបត្តិតាមសាលក្រមជាច្រើនរបស់តុលាការនេះមក គណៈកម្មការរបស់ដើមចោទបានចូលរួមនិងផ្តល់ជំនួយផ្នែកបច្ចេកទេស ដើម្បីជួយរដ្ឋនេះតាមរយៈកាតព្វកិច្ចផលិតរបស់គាត់។ តាមការកត់សម្គាល់ វាបានតម្រូវឲ្យមានអន្តរាគមន៍ពីអភិបាលរដ្ឋ

ល្វីស៊ាណា ដើម្បីដំណើរការនេះកើតឡើងបាន។ តាមការពិត ការិយាល័យរបស់អភិបាលរដ្ឋនិងគណៈកម្មការរបស់ដើមចោទបានព្រមព្រៀងគ្នាក្នុងការធ្វើការងារយ៉ាងស្អិតរមួត ដើម្បីស្វែងរកផលប្រយោជន៍រួម។ សូមមើល State of La., Off. of the Governor, Mot. to File Mem. in Supp., Rec. Doc 4916។

ពាក្យបណ្តឹងរបស់គណៈកម្មការដើមចោទបញ្ជាក់យ៉ាងពិស្តារ អំពីការងារដ៏ធំមហិមា និងការនិយោគទុនយ៉ាងច្រើនដែលគណៈកម្មការ របស់ដើមចោទបានឈានមុខតាំងពីការបង្កើតបណ្តឹងសមូហភាពនេះនៅខែសីហា ឆ្នាំ2010[1]។ វាគ្មានបញ្ហាទេដែលគណៈកម្មការរបស់ដើមចោទបានបំពេញកាតព្វកិច្ចជាតំណាងយ៉ាងសកម្មដើម្បីផលប្រយោជន៍របស់ដើមចោទឲ្យបានល្អបំផុត ទាំងឯកជននិងរដ្ឋាភិបាល។

តុលាការមិនទាន់សម្រេចនៅពេលនេះទេ ថាតើគាំទ្រប្រាក់កម្រៃរួម ឬការចំណាយរួមទៅគណៈកម្មការរបស់ដើមចោទ (PSC) ដែរឬទេ។ បញ្ហាទាំងនោះត្រូវបានលើកទៅថ្ងៃក្រោយ។ ប៉ុន្តែវាជាការចាំបាច់ណាស់ក្នុងការបង្កើតយន្តការមួយដើម្បីប្រមូលមូលនិធិមួយ ដែលអាចធ្វើឲ្យមានការបង់ប្រាក់កម្រៃនិងចំណាយនានានៅពេលណាមួយសមរម្យ។ មុនពេលដែលសេចក្តីសម្រេចណាមួយត្រូវបានធ្វើឡើង វានឹងមានការខ្វះខាតលើការផ្តល់នីតិវិធីពីរក្នុងរឿងក្តីនូវការកត់ត្រានិងឱកាសក្នុងការចូលស្តាប់នូវបញ្ហានានាទាក់ទងនឹងសំណើទាំងឡាយអំពីការចំណាយប្រាក់ពីមូលនិធិរួមនោះ។ ដូចពាក្យបណ្តឹងរបស់គណៈកម្មការរបស់ដើមចោទបានបង្ហាញ គឺថាវាអាចមានលទ្ធផលជាច្រើននៅក្នុងរឿងក្តីនេះដែលក្នុងនោះការកាត់នូវប្រាក់មូលនិធិនោះនឹងត្រូវកាត់បន្ថយ ឬ ក៏អាចត្រូវបានផ្តល់ឡើងវិញឲ្យគ្រប់ចំនួនពីបុគ្គលណាដែលតម្រូវឲ្យបរិចាក។

អភិបាលរដ្ឋល្វីស៊ាណាបានដាក់បណ្តឹងឆ្លើយតបចំពោះពាក្យបណ្តឹងរបស់គណៈកម្មការដើមចោទ (PSC) វិញ ថាគាត់មិនបដិសេធអំពីសំណើលើការកាត់ប្រាក់4%ទេ រហូតដល់ពេលដែលផ្នែកមួយចំនួននៃការស្តារឡើងវិញដោយរដ្ឋត្រូវបានអនុគ្រោះ។ គណៈកម្មការរបស់ដើមចោទ (PSC) បានផ្តល់មតិទៅ

---

[1] កាលថ្ងៃទី07 វិច្ឆកា ឆ្នាំ2011 PSC បានរាយការណ៍ "មានមេធាវីចំនួន 340នាក់មកពី 90ក្រុមហ៊ុនមេធាវីខុសៗគ្នា បានវិនិយោគពេលវេលាច្រើនជាង 230.000 ម៉ោង និងទឹកប្រាក់ច្រើនជាង11.54 លានដុល្លារ ដោយរួមគ្នាចំណាយសម្រាប់ផលប្រយោជរួមរបស់ដើមចោទនិងភាគីបណ្តឹង.....ម្យ៉ាងទៀត PSC សមាជិកនានានិងសមាជិកនៃក្រុមការងារផលប្រយោជន៍រួម និងអ្នកសម្របសម្រួលបានតម្រូវឲ្យបង់ប្រាក់ប្រហាក់ប្រហែល1.5 លានក្នុងការមិនបានបង់ដែលកំពុងដំណើរការ។ ព្រមជាមួយគ្នានេះដែរ PSC សមាជិកនិងក្រុមមេធាវីផលប្រយោជន៍រួមផ្សេងៗបានបរិច្ចាកនិងបន្ថែម1.8លានក្នុងគណនីរួមមួយសម្រាប់ចំណាយលើកក្រោយតាមការតម្រូវ " PSC's Memo. in Supp. p. 9 & n.10, Rec. Doc. 4507-1 at 12 & n.10។

តុលាការថាពួកគាត់ឯកភាពជាមួយជំហររបស់អភិបាលរដ្ឋ និងបានដាក់សំណើការកែប្រែសាលក្រមបណ្ដោះអាសន្ននេះ។ អគ្គមេធាវីរបស់រដ្ឋអាឡាបាម៉ានបានផ្ដល់មតិថាគាត់មិនបដិសេធលើសំណើរអំពីការកាត់ប្រាក់នេះទេ។ ដោយមូលហេតុនេះ តុលាការនឹងចេញសាលក្រមមួយដែលតម្រូវឲ្យមានការកាត់ប្រាក់4% នូវការបរិច្ចាកដោយរដ្ឋល្វីស៊ាណា និងអាឡាបាម៉ាដោយមានការលើកលែងខ្លះៗដែលបានកំណត់និងបានស្នើដោយអភិបាលរដ្ឋល្វីស៊ាណា[2]។

ចំណែកឯបញ្ហាផ្សេងទៀត ភាគីមួយចំនួនបានអះអាងថា បណ្ដឹងដែលត្រូវបានដោះស្រាយតាមរយៈស្ថាបនសម្រួលបណ្ដឹងនៅតំបន់ឈូងសមុទ្រ (GCCF) មិនត្រូវជាកម្មវត្ថុនៃការកាត់ប្រាក់ឡើយ។ សូមមើលឧទាហរណ៍ ឯកសារយោងលេខ 4682។ ពួកគេបានកត់សម្គាល់ថាច្បាប់ស្ដីពីការបំពុលដោយសារប្រេង (“OPA”) នៃឆ្នាំ1990 តម្រូវឲ្យ BP បង្កើតនិតិវិធីមួយសម្រាប់ទទួល និងដោះស្រាយពាក្យបណ្ដឹង 33 U.S.C. § 2714 និង បានតម្រូវឲ្យដើមចោទនានាបង្ហាញពាក្យបណ្ដឹងរបស់ពួកគាត់ទៅ BP នៅក្នុងសវនការ 33 U.S.C. §2713។ ដូច្នេះ វាមានអំណះអំណាងថា ការដោះស្រាយរឿងក្ដីដែលបានធ្វើឡើងតាមរយៈ GCCF មិនមានលទ្ធផលលើផលប្រយោជន៍កិច្ចការរួមឡើយ។

គណៈកម្មការរបស់ដើមចោទ (PSC) បានតស៊ូមតិយ៉ាងខ្លាំងក្លាក្នុងនាមបុគ្គលដែលដាក់ពាក្យបណ្ដឹងទៅស្ថាបនសម្រួលបណ្ដឹងនៅតំបន់ឈូងសមុទ្រ(GCCF) ហើយបន្តអនុវត្តសម្ពាធទាំងវិស័យសាធារណៈ និងឯកជន ដើម្បីកែលម្អដំណើរការដោះស្រាយបណ្ដឹងរបស់ស្ថាបនសម្រួលបណ្ដឹងនៅតំបន់ឈូងសមុទ្រ (GCCF)។ ឧទាហរណ៍៖ គណៈកម្មការរបស់ដើមចោទ (PSC) បានបញ្ចុះបញ្ចូលនិងអះអាងយ៉ាងសកម្មលើការតម្លើង ការត្រួតពិនិត្យ និងតាមដានការសម្រួលបណ្ដឹងនៅតំបន់ឈូងសមុទ្រ (GCCF) និង

[2] អគ្គមេធាវីរបស់រដ្ឋល្វីស៊ាណាបានបដិសេធនូវការតម្រូវឲ្យគាត់បង់4% “កម្រៃសេវា” ដែលគាត់អះអាងថា បំពាននឹងអធិបតេយ្យភាពរបស់រដ្ឋល្វីស៊ាណា។ ការអះអាងនេះមិនមានភស្តុតាងឡើយ។ ដោយយោងតាម សាលក្រមរបស់តុលាការ តុលាការមិនកំណត់តម្លៃកម្រៃនានាដែលតិចជាងតម្លៃកម្រៃសេវា។ សូមរំលឹក ឡើងវិញថា4% គឺជាការបរិច្ចាកដែលត្រូវកាត់ចូលមូលនិធិជាបណ្ដោះអាសន្នមួយដែលក្នុងនោះ ប្រាក់កម្រៃ ទាំងនេះអាចត្រូវបែងចែកតាមការចាំបាច់។ ដើម្បីទទួលយកបាននូវអំណះអំណាងរបស់អគ្គមេធាវី របស់រដ្ឋ ល្វីស៊ាណាគួរមានតួនាទីប្រើប្រាស់ប្រាក់កម្រៃជំនួសឲ្យការខិតខំរបស់ PSC ដែលដោះស្រាយបណ្ដឹងរបស់ រដ្ឋឈានមុខគេ។ តុលាការបង្ហាញថាអគ្គមេធាវីមិនមានឆន្ទៈលើការបង់ប្រាក់កម្រៃសេវាផ្នែកច្បាប់ទៅមេធាវីជាច្រើនដែលមកពីក្រុមហ៊ុនមេធាវីប្រាំខុសគ្នាដែលតំណាងឲ្យគាត់ក្នុង MDLឡើយ។ ផ្ទុយមកវិញ អគ្គមេធាវីរបស់រដ្ឋអាឡាបាម៉ាដែលជាអ្នកតំណាងឲ្យផលប្រយោជន៍រដ្ឋរបស់គាត់តែមួយប៉ុណ្ណោះក្នុងការសហការជាមួយ PSC។

Kenneth Feinberg/Feinberg Rozen, LLP។ កិច្ចប្រឹងប្រែងនេះ យ៉ាងហោចណាស់ បានទទួលជោគជ័យមួយផ្នែក

ឧទាហរណ៍៖ នៅថ្ងៃទី02 ខែ កុម្ភៈ ឆ្នាំ2011 តុលាការបានសម្រេចលើពាក្យបណ្ដឹងរបស់គណៈកម្មការរបស់ដើមចោទ(PSC) (ជាផ្នែក)និងចេញសាលក្រមទៅស្ថាបនសម្រួលបណ្ដឹងនៅតំបន់ឈូងសមុទ្រ (GCCF) និង BPថា៖

(1). ហាមទំនាក់ទំនងដោយផ្ទាល់ជាមួយដើមចោទណាមួយដែលពួកគាត់ដឹងឬគួរដឹង ដែលត្រូវបានតំណាងដោយក្រុមប្រឹក្សា ទោះបីយ៉ាងណាក៏ដោយ ក៏ដើមចោទបានដាក់ពាក្យបណ្ដឹងឬ ទាមទារផ្លូវការណាមួយហើយ

(2) ហាមទំនាក់ទំនងទៅ GCCF, Ken Feinberg ឬ Feinberg Rozen, LLP (ឬតំណាងរបស់ពួកគេ) ទោះបីជាអព្យាក្រឹត្យ ឬឯករាជ្យពេញលេញពី BPក៏ដោយ។ វាគួរតែបើកចំហរាល់ទំនាក់ទំនងទាំងអស់ ទោះបីជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ក៏ដោយ ដែលថាភាគីជាតំណាងរបស់ BP ត្រូវបំពេញកាតព្វកិច្ចដូចគ្នានឹងភាគីវិវាទផ្ទាល់ ដោយយោងតាមច្បាប់ស្ដីពីការបំពុលដោយសារប្រេង (OPA) នៃឆ្នាំ1990។

(3) ចាប់ផ្ដើមទំនាក់ទំនងជាមួយសមាជិកក្រុមនូវពាក្យពេចន៍ដែលបុគ្គលនីមួយៗ មានសិទ្ធិប្រឹក្សាជាមួយមេធាវីដែលគាត់បានជ្រើសរើសពីមុន ដើម្បីទទួលដោះស្រាយរឿងក្ដីឬចុះហត្ថលេខាលើការដោះលែង តាមសិទ្ធិស្របច្បាប់។

(4) ហាមទទួលការផ្ដល់មតិ ឬគំនិតផ្នែកច្បាប់ជូនដើមចោទដែលមិនបានបង្ហាញខ្លួន រួមមានការផ្ដល់គំនិតដែលដើមចោទមិនអាចជួលមេធាវីម្នាក់បាន។

(5) ប្រកាសឲ្យបានពេញលេញទៅដើមចោទនានាអំពីជម្រើសច្បាប់ស្ដីពីការបំពុល ដោយសារប្រេង (OPA) នៃឆ្នាំ1990 ប្រសិនបើពួកគាត់មិនទទួលយកការបង់ប្រាក់ចុងក្រោយ រួមទាំងការដាក់ពាក្យបណ្ដឹងមួយដែលរារាំងដល់បណ្ដឹង MDL 2179។

(6) ផ្ដល់គំនិតដល់ដើមចោទដែលមេធាវីមិនយកកម្រៃសេវា និងតំណាងមកពីសហគមន៍នៅតែជួយដើមចោទរបស់ GCCF ត្រូវបានទទួលការឧបត្ថម្ភដោយផ្ទាល់ ឬ មិនផ្ទាល់ពី BP។

យោងឯកសារលេខ 1098 ទំព័រ14។

គណៈកម្មការរបស់ដើមចោទ (PSC) បានតស៊ូមតិជោគជ័យក្នុងនាមជាតំណាងឲ្យដើមចោទជាជនជាតិវៀតណាម និង ដើមចោទមិនចេះភាសាអង់គ្លេស និងបានធ្វើឲ្យ GCCFប្រើប្រាស់ទម្រង់បកប្រែការណែនាំដោយមានការជឿជាក់ជាដើម។ PSC បានរៀបចំនូវការបកប្រែដល់ដើមចោទផងដែរ។ PSC បានតស៊ូមតិឲ្យមានការត្រួតពិនិត្យយ៉ាងពេញលេញ និង តម្លាភាពមួយរបស់ GCCF ព្រមការអនុវត្តលើការដោះស្រាយពាក្យបណ្តឹងផងដែរ។ ហើយជាមួយគ្នាផងនោះក្រសួងយុត្តិធម៌របស់សហរដ្ឋអាមេរិកបានទាក់ទាញលោក Feinberg ឲ្យយល់ព្រមលើការត្រួតពិនិត្យនោះដែលបច្ចុប្បន្នកំពុងតែដំណើរការល្អ។ PSCបានតស៊ូមតិ ជោគជ័យម្តងទៀតសម្រាប់ GCCF ក្នុងការប្រើប្រាស់និយាម (ស្តង់ដារ) ហេតុ និងផលឲ្យកាន់តែមានលក្ខណៈសេរីក្នុងការវាយតម្លៃបណ្តឹង និង មានភាពឈានមុខលើអំណះអំណាងកាន់តែមានហេតុផលប្រហាក់ប្រហែលគ្នានៅក្នុងដំណើរការបណ្តឹងសមូហភាព (MDL)។ សូមមើលសាលក្រមថ្ងៃទី26 ខែសីហា ឆ្នាំ2011 ឯកសារយោងលេខ 3830 ទំព័រ 32 ដល់ 33។ PSCបានអះអាងយ៉ាងជោគជ័យលើការអនុវត្តច្បាប់សមុទ្រទូទៅ និងសំណងការខូចខាតនានាដែលអាចមាន។ *សាលក្រមដ៏ដែលនៅទំព័រ 18 ដល់ 27*។ ថ្វីបើ GCCF មិនបង់សំណងខូចខាតក៏ដោយ ក៏ PSC នៅតែអាចបង្ហាញថាការរកឃើញនេះបង្កើនតម្លៃដោះស្រាយរឿងក្តីថាបណ្តឹងត្រូវបានសងសំណងខូចខាត។

យោងតាមកាលៈទេសៈពិសេសនានានៃរឿងក្តីនេះ វាមានភាពអយុត្តិធម៌ក្នុងការអនុញ្ញាតឲ្យភាគីទាំងឡាយទទួលបានផលប្រយោជន៍ពីសកម្មភាពរបស់ PSCទាំងនោះ ប៉ុន្តែជៀសវាងការបរិច្ចាកមូលនិធិរួមយ៉ាងងាយ ពីព្រោះពួកគាត់អាចដោះស្រាយដោយផ្ទាល់ជាមួយ GCCF និង ជៀសវាងការដាក់ពាក្យបណ្តឹងនៅក្នុង MDL។ ភាគីដ៏ទៃទៀតដែលបានដាក់ពាក្យបណ្តឹងនៅក្នុង MDL ប៉ុន្តែបន្ទាប់មកដកពាក្យបណ្តឹងវិញ ដោយសារពួកគាត់បានដោះស្រាយជាមួយ GCCF។ ម្តងទៀត ភាគីទាំងនោះអាចទទួលផលប្រយោជន៍ពីការងាររួមដែលបានធ្វើដោយ PSC។

អំណះអំណាងពាក់ព័ន្ធនឹងតុលាការបានសម្រេចសាលក្រមក្នុងការកាត់ប្រាក់នូវ (1) រឿងក្តីដែលបានប្តឹងទៅតុលាការរបស់រដ្ឋ បានប្តូរទៅតុលាការនេះ (ឬប្តូរទៅតុលាការសហព័ន្ធ បន្ទាប់មកផ្ទេរទៅតុលាការនេះ)

និងមានការពន្យាបណ្ដឹងដើម្បីបញ្ជូនត្រឡប់ទៅវិញ និង (2) រឿងក្ដីដែលបានប្ដឹងទៅតុលាការរដ្ឋដែលមិនត្រូវបានផ្លាស់ប្ដូរ។ *សូមមើល ឯកសារយោងលេខ 4657។*

ក្នុងប្រភេទរឿងក្ដីទី1 តុលាការយល់ព្រមជាមួយនឹងទស្សនៈរបស់ *In re Zyprexa Products Liability Litigation*, 594 F.3d 113 (2d Cir. 2010)។ ក្នុងរឿងក្ដីនេះ តុលាការដំបូងទាមទារសំណងខូចខាតដល់មេធាវី រួមមានការបង្កើតមូលនិធិរួមមួយ នៅក្នុងក្រុមហ៊ុនមេធាវីមួយដែលមានពាក្យបណ្ដឹងចំនួន6 ត្រូវរង់ចាំការបញ្ជូនត្រឡប់មកវិញ។ ក្រុមហ៊ុនមេធាវីបានប្ដឹងទាមទារសិទ្ធិដែលត្រូវបំពេញ តតាំងនឹងសេចក្ដីសម្រេចរបស់តុលាការដំបូង។ ទោះបីតុលាការឧទ្ធរណ៍បានបដិសេធនូវការទាមទារ សិទ្ធិដែលត្រូវបំពេញ[3] នោះក៏ដោយ ក៏ទស្សនៈនោះត្រូវបានទទួលការគាំទ្រ ដោយយោងតាមសាលក្រម ដដែល ទំព័រ119 ដែលបានឯកភាពលើសេចក្ដីសម្រេចរបស់តុលាការដំបូង។

ចៅក្រមបានពន្យល់ថា៖

> ប្រសិនបើ [តុលាការដំបូង] ត្រូវ [កំណត់ថាតុលាការដែលមានសមត្ថកិច្ច] មុនពេលតុលាការចេញសេចក្ដីសន្និដ្ឋានលើរឿងក្ដីនេះដោយផ្អែកលើតែអង្គហេតុ និងអង្គច្បាប់ តុលាការត្រូវមានអំណាចក្នុងការចេញសេចក្ដីព្រាងលើបង្គាប់ដែលបានកត់ត្រាទុកអំពីអង្គហេតុ និងការកំណត់ចុងក្រោយលើសេចក្ដីសន្និដ្ឋាននេះ។
>
> ......
>
> ដូច្នេះ សាលក្រមរបស់តុលាការដំបូងមួយដែល "ផ្អែកលើតែអង្គហេតុ និងអង្គច្បាប់" អាចទទួលយកបាន ទោះបីសេចក្ដីសន្និដ្ឋានចុងក្រោយថាតុលាការខ្វះសមត្ថភាពលើការដោះស្រាយរឿងក្ដី។
>
> ក្នុងករណីនេះ ការប្ដឹងតវ៉ាលើសាលក្រមបានកំណត់អំពីការវាយតម្លៃយ៉ាងសាមញ្ញក្នុងគោលបំណងបង្កើតមូលនិធិមួយដែលអាចត្រូវបានប្រើប្រាស់ដើម្បីឧបត្ថម្ភមេធាវីទាំងឡាយណាដែលជាទូទៅបានខិតខំប្រឹងប្រែងក្នុងការការពារផលប្រយោជន៍ដើមចោទ *Zyprexa*។ វាមានការពាក់ព័ន្ធតិចតួចជាមួយនឹងអង្គហេតុ និងអង្គច្បាប់ចុងក្រោយ ជាងសាលក្រមដែលគាំទ្រកម្រៃសេវារបស់មេធាវីដែលជាបញ្ហាបន្ទុកបន្ថែម លើតុលាការក្នុងការរក្សាយុត្តាធិការ ទោះបីជាតុលាការត្រូវបានគេចាត់ទុកថាមានការខ្វះសមត្ថភាពលើយុត្តាធិការក៏ដោយ។ វាមិនមានការរាំងស្ទះដល់អ្នកប្ដឹងពីការលំបាកក្នុងសំណើបរិច្ចាកលើមូលនិធិ ដោយមូលហេតុថា ពួកគាត់

[3] ក្រុមហ៊ុនមេធាវីមិនបានផ្ដល់ឲ្យយើងនូវអង្គហេតុរឹងមាំឬអង្គច្បាប់ដែលយើងអាចសន្និដ្ឋានថាតុលាការដំបូងយកអំណាចរបស់គាត់ឬបានបំពានយ៉ាងច្បាស់នូវនន្ទានុសិទ្ធិរបស់គាត់។ *Id.* at 118-19.

មិនទទួលផលប្រយោជន៍ពីការខ្វះខ្នែងរបស់ក្រុមប្រឹក្សាដែលកំណត់ថាអ្នកណាគួរទទួលការបរិច្ចាក នេះ។ យ៉ាងតិចណាស់ក្នុងកាល:ទេស:ទាំងនោះ ការប្ដឹងជំទាស់នឹង សាលក្រមជាបន្ទុក បន្ថែមលើអង្គហេតុនិងអង្គច្បាប់និងអំណាចរបស់តុលាការដំបូង។

ការកំណត់របស់តុលាការដំបូងដើម្បីស្របតាមការគិតពិចារណាលើការជម្រុញយុត្តាធិការ ជួនកាលវាផ្អែកលើឆន្ទានុសិទ្ធិរបស់តុលាការ។ ថ្វីបើមានការផ្ដល់មតិដល់តុលាការដំបូង ក្នុងការដឹកនាំសមត្ថកិច្ចតាំងពីការដំណើការរឿងក្ដីដំបូងក៏ដោយ ក៏តុលាការដំបូងមានវិសាលភាព ទូលំទូលាយណាស់ក្នុងការគ្រប់គ្រងសំណុំឯកសាររបស់ខ្លួនដែរក្នុង "លក្ខខណ្ឌសន្សំពេលវេលានិង ខិតខំខ្វះខ្នែងរបស់ខ្លួនដើម្បីក្រុមប្រឹក្សានិងភាគីវិវាទ"។ ឥទ្ធិពលនៃការគិតពិចារណាក្នុងករណីនេះ និងបណ្ដឹងសមូហភាពនានានិងបទល្មើសកម្រឹតធ្ងន់ ជួនកាលអាចមានការផ្ដល់យោបល់ខុសៗគ្នា។

ការបំពានបទល្មើសកម្រឹតធ្ងន់ជាបណ្ដឹងដ៏ពិបាកដែរ។ ដើមចោទត្រូវប្ដឹង ទៅស្ថាបន ណាដែលពួកគាត់គិតថាចូលចិត្ត ដូចជាតុលាការនានាក្នុងរដ្ឋ។ ចុងចម្លើយបានប្ដូរនូវ ការគិតពិចារណាដោយប្ដូរការដាក់ពាក្យបណ្ដឹងទៅតុលាការសហព័ន្ធវិញក៏មាន។ ជំហានទាំងនេះ បណ្ដាលឲ្យមានចំនួនបណ្ដឹងដែលត្រូវពន្យាឬបញ្ជូនមកវិញច្រើនដូចក្នុងករណីបណ្ដឹង សមូហភាព នេះ (MDL)។ជានេះទៀត អ្នកប្ដឹងម្នាក់បានដាក់ ពាក្យបណ្ដឹងហើយត្រូវពន្យាពេល លើសពី50 ដង នៃរឿងក្ដីរបស់ *Zyprexa*។

......

ចៅក្រមរបស់តុលាការដំបូងគ្រប់គ្រងស្ថានភាពស្មុគស្មាញយ៉ាងសមស្របអាចសរុបថា ពេលវេលារបស់តុលាការជាពិសេសគឺចាប់ពីពេលដំណើរការរឿងក្ដីដំបូងមក ជាការចំណាយពេល ដ៏ល្អលើអង្គហេតុ ជាជាងការសម្រេចលើពិន្ទុឬពាក្យបណ្ដឹងរាប់រយត្រូវបាន បញ្ជូនមកវិញ..... ការសម្រេចលើបណ្ដឹងនីមួយៗត្រូវឆ្លើយតបទៅនឹងបញ្ហារួមដូចគ្នាទាំងអស់ ឬ បណ្ដឹងជាច្រើន តម្រូវឲ្យមានការចំណាយពេល និងធនធានច្រើនដែលធ្វើឲ្យរាំងស្ទះដល់ដំណើរការបណ្ដឹង ទាំងមូល។ ការពន្យាពេលនេះអាចរារាំងដល់បណ្ដឹងសមូហភាព(MDL)ដែរ ដើម្បី "ជម្រុញ ភាពយុត្តិធម៌ និងប្រសិទ្ធភាពនៃទង្វើ" ដែលពាក់ព័ន្ធបញ្ហារួមរបស់អង្គហេតុ។

នៅពេលដែលបណ្ដឹងនីមួយៗផ្អែកលើអង្គហេតុរបស់ខ្លួន ខ្ញុំមិនអាចនិយាយថាសេចក្ដី សម្រេចរបស់តុលាការដំបូងបានផ្ដល់អទិភាពនូវការដោះស្រាយបណ្ដឹងរបស់ *Zyprexa* ចំនួនរាប់ពាន់ករណី ដើម្បីទៅធ្វើការសម្រុះសម្រួលឬរក្សាទុកបណ្ដឹងទាំងនោះដើម្បីបញ្ជូនត្រឡប់ មកវិញដោយផ្អែកលើឆន្ទានុសិទ្ធិលើការគ្រប់គ្រង សំណុំឯកសារ។

យោងទៅលើឯកសារដដែល ទំព័រ126 ដល់ 128 (ថៅក្រម Kaplan ) (មិនមាន footnotes និងការចម្លងឡើយ)។ តុលាការយល់ព្រមជាមួយនឹងការវិភាគរបស់ថៅក្រម Kaplan។ ដូច្នេះ ការកាត់ប្រាក់មូលនិធិត្រូវអនុវត្តចំពោះបណ្តឹងទាំងនោះត្រូវបានពន្យាពេលនិងរងចាំបញ្ជូនមកវិញ។

ដូចគ្នានឹងប្រភេទរឿងក្តីទីពីរ នៅចំពោះមុខតុលាការនានារបស់រដ្ឋ តុលាការដំបូងក្នុងរឿងក្តី *In re Genetically Modified Rice Litigation* បានតម្រូវឲ្យមានមេធាវីទាំងអស់ - រួមទាំងក្នុងតុលាការរបស់រដ្ឋដល់អ្នកដែលទទួលផលប្រយោជន៍ពីការងាររបស់ក្រុមប្រឹក្សា - ដែលត្រូវបានតែងតាំងឡើងដើម្បីបរិច្ចាកទៅមូលនិធិភលប្រយោជន៍រួមមួយ ដើម្បីជៀសវាងការបង្កើនភាពអយុត្តិធម៌ ដូច្នេះហើយមូលនិធិនេះគឺបម្រើឲ្យផលប្រយោជន៍យុត្តិធម៌។ ប៉ុន្តែ វាមិនអាចអនុវត្តទៅបានដោយសារតែកង្វះខាតសមត្ថកិច្ចរបស់តុលាការ។ ដូចជា No. 4:06-md-1811, 2010 WL 716190 at *4-5 (E.D. Mo.Feb. 24, 2010) (citing *In re Showa Denko K.K. L-Tryptophan Prods. Liab. Litig.-I*, 953 F.2d162 (4th Cir. 1992); *Hartland v. Alaska Airlines*, 544 F.2d 992 (9th Cir. 1976))។ ផ្ទុយមកវិញ សំណុំរឿង *In re Latex Gloves Products Liability Litigation* ត្រូវបានតុលាការតម្រូវឲ្យមេធាវីមួយដែលកាន់រឿងក្តីនានាពីមុនមកទាំងនៅក្នុងតុលាការសហព័ន្ធ និងតុលាការរបស់រដ្ឋ បរិច្ចាកប្រាក់ក្នុងគណនីបម្រុងមួយសមាមាត្រនឹងដំណើរការដោះស្រាយវិវាទដើម្បីបង្កើនការចូលរួមក្នុងការស្វែងរកឯកសារទាំងឡាយដែលទុកក្នុងឃ្លាំង។ សំណុំរឿងលេខ No. 1148, 2003 U.S. Dist. LEXIS 18118 (E.D. Pa. Sept. 5, 2003) ។ តុលាការបានពន្យល់ ៖

> [សេចក្តីបង្គាប់លើការគ្រប់គ្រងសំណុំរឿង] ត្រូវបានរឹតត្បិតដល់ដើមចោទណាដែលបានចូលទៅរកឯកសារដែលនៅក្នុងឃ្លាំង។ ដូចសំណុំណុំរឿងរបស់ម៉ូរ៉ាន ទីប្រឹក្សាចុងចោទភាគច្រើន តំណាងឲ្យតុលាការរដ្ឋ ក៏ដូចជាចុងចោទតុលាការសហពន្ធ័ដែរ។ [ក្រុមប្រឹក្សា] ដែលទទួលបានការអនុញ្ញាតឲ្យស្វែងរកព័ត៌មាន នៅក្នុងរឿងក្តីរបស់ខ្លួនដោយគ្មានបង់ប្រាក់។ Special Master បានកត់ត្រាថា [សេចក្តីបង្គាប់លើការគ្រប់គ្រង] សំណុំរឿងមានបំណងជៀសវាង "ការបង្ខំទៅក្រុមប្រឹក្សារួមមានលោក Benjamin ដែលមានបណ្តឹងត្រូវបានពន្យាពេលទាំងនៅតុលាការរបស់រដ្ឋ និងតុលាការសហព័ន្ធ"។

*Id.* at *5; *see also* Case Mgmt. Order No. 17 ¶ 3(f)(3), *In re Fosamax Prods. Liab. Lit.*, No.1:06-md-1786 (S.D.N.Y. Apr. 28, 2011), ECF No. 1012 ("ក្រុមប្រឹក្សារបស់ដើមចោទដែលគ្មានសំណុំរឿងនៅក្នុង MDL ដែលប្រើប្រាស់ទិដ្ឋភាពរបស់ការងារលើផលប្រយោជន៍រួម MDL ឬដែលចូលរួមក្នុងដំណោះស្រាយសហប្រតិបត្តិការ PSC មួយ ហើយដែលមិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការវាយតម្លៃ ត្រូវជាកម្មវត្ថុ [9% នៃការវាយតម្លៃមូលនិធិនៃការកាត់ប្រាក់]"។ ក្នុងករណីនេះ មជ្ឈមណ្ឌលតុលាការសហព័ន្ធបានសរសេរថា៖

> តុលាការអាចណែនាំការបរិច្ចាកដោយចុងចម្លើយ ឬដោយក្រុមប្រឹក្សាដើមចោទ ក្រៅពីបុគ្គលដែលត្រូវទទួលការចំណាយលើការដោះស្រាយវិវាទ។ **កម្រៃសេវា មិនអាចត្រូវបានដាក់កំណត់ដោយចៅក្រមទៅលើមេធាវីណាដែលគ្មានបណ្តឹងនៅក្នុង MDL <u>និង</u>មិនបានប្រើប្រាស់ឯកសាររបស់មេធាវីសហព័ន្ធឡើយ។**

Fed. Judicial Ctr., *Managing Multidistrict Litigation in Products Liability Cases, A Pocket Guide for Transferee Judges* 14-15 (2011) (បានបន្ថែម)។

យោងតាមតម្រូវការលើការកាត់ប្រាក់នេងមិនអនុវត្តចំពោះបណ្តឹងទៅតុលាការរបស់រដ្ឋទេ នៅពេលដែលក្រុមប្រឹក្សារបស់ដើមចោទមានឬមិនមានបណ្តឹងក្នុង MDL និងដែលមិនបានចូលរួមក្នុងឬបានចូលទៅការស្វែងរកឯកសារនៅក្នុង MDL។

យោងតាមអត្ថបទខាងលើ

**ត្រូវបានសម្រេចថា** ចុងចម្លើយត្រូវបង់និងតម្កល់ចំនួនទឹកប្រាក់ស្មើនឹងបួនភាគរយ (4%) នៃបរិមាណទឹកប្រាក់នៃការដោះស្រាយរឿងក្តីទាំងស្រុង ប្រាក់ប្រដាប់ក្តីនិងប្រាក់ចំណាយផ្សេងៗដែលបានចំណាយនៅនិងបន្ទាប់ពីថ្ងៃទី07 ខែវិច្ឆកា ឆ្នាំ2011 ដោយឬក្នុងនាមចុងចម្លើយម្នាក់ឬច្រើនទៅរដ្ឋអាឡាបាម៉ា ឬរដ្ឋល្វីស៊ាណា ឬស្ថាប័នរដ្ឋាភិបាលរបស់ពួកគេ ដែលបានកើតឡើងនូវគ្រោះមហន្តរាយ Macondo / *Deepwater Horizon*[4] នៅក្នុងគណនីរបស់តុលាការ ដើម្បីបង្កើតមូលនិធិដែលបានមកពីកម្រៃលើ

[4] សេចក្តីតម្រូវឲ្យបង់ "ប្រាក់កក់តាមចំនួនភាគរយ" ដែលត្រូវបានកណត់ ដើម្បីទ្រទ្រង់ភាគីនានាដែលមានភាពវៃ ឆ្លាតក្នុងការចរចាដោះស្រាយបណ្តឹង។ សន្មត់ថាដើមចោទនឹងមានបំណងចរចាវិវាទជាមួយចុងចម្លើយមួយឬច្រើនដែលចុងចម្លើយអាចយល់ព្រមបង់ប្រាក់កម្រៃលើផលប្រយោជន៍រួម (និង/ឬកម្រៃសេវាមេធាវីផ្សេងៗ)លើសពីលើដំណោះស្រាយបណ្តឹង ដែលជាផ្នែកមួយនៃដោះស្រាយបណ្តឹងតាមរយៈការចរចា។ ប៉ុន្តែក្នុងព្រឹត្តការណ៍ដែលចុងចម្លើយមិនមានមូលនិធិលើការដោះស្រាយបណ្តឹងប្រាក់បម្រុង

ផលប្រយោជន៍រួម និងការចំណាយណាដែលបានចាយ ដែលបានការគាំទ្រដោយតុលាការតាមពេលវេលាសមរម្យ យោងតាមនីតិវិធីដែលបានកំណត់ដោយតុលាការនាពេលអនាគត។

មិនមានបរិមាណប្រាក់ត្រូវបានកាត់ប្រាក់ ឬរក្សាពីរដ្ឋអាឡាបាម៉ាឬរដ្ឋល្វីស៊ាណាទេ។ មិនមានបរិមាណប្រាក់ពិតប្រាកដដែលបានមកពីការកាត់ប្រាក់ឬរក្សាឡើយ ទៅរដ្ឋផ្ទាល់ពីភាគីដែលត្រូវទទួលខុសត្រូវដើម្បីសងទៅរដ្ឋសម្រាប់ការចំណាយនានា ការចំណាយលើទីភ្នាក់ងារ ឬចំណាយលើការចូលក្នុងដំណើរការ NRDA បានកើនឡើង ។

**ត្រូវបានសម្រេចបន្ថែមថា** ចុងចម្លើយឬទីភ្នាក់ងារដែលតំណាងឲ្យចុងចម្លើយត្រូវបង់និងតម្កល់បរិមាណប្រាក់ស្មើនឹង 6% នៃបរិមាណទឹកប្រាក់នៃការដោះស្រាយរឿងក្តីទាំងស្រុង ប្រាក់ប្រដាប់ក្តីនិងប្រាក់ចំណាយផ្សេងៗដែលបានចំណាយនៅនិងបន្ទាប់ពីថ្ងៃទី07 ខែវិច្ឆកា ឆ្នាំ2011 ដោយឬក្នុងនាមចុងចម្លើយម្នាក់ឬច្រើនទៅឲ្យដើមចោទ សមាជិកក្រុម ឬដើមចោទផ្សេងទៀត ដែលបានកើតឡើងក្នុងគ្រោះមហន្តរាយ Macondo / *Deepwater Horizon* (ដោយលើកលែងការដោះស្រាយបណ្តឹង ការចេញសាលក្រមឬការចំណាយផ្សេងៗទៅលើសហរដ្ឋអាមេរិក) នៅក្នុងគណនីរបស់តុលាការ ដើម្បីបង្កើតមូលនិធិដែលបានមកពីកម្រៃលើផលប្រយោជន៍រួមនិងការចំណាយណាដែលបានចាយ ដែលបានការគាំទ្រដោយតុលាការ តាមពេលវេលាសមរម្យ យោងតាមនីតិវិធីដែលបានកំណត់ដោយតុលាការ[5] នាពេលអនាគត។ ជាពិសេស តម្រូវការនៃការកាត់ប្រាក់នេះ អនុវត្តចំពោះរាល់បណ្តឹងទាំងអស់ដែលបានដាក់ឬប្តូរទៅតុលាការសហព័ន្ធដែលជាបណ្តឹងសម្ហភាពទាំងស្រុង ឬមួយចំណែក ទោះបីជាបណ្តឹងដែលត្រូវបញ្ជូនមកវិញត្រូវបានប្តឹង ដើមចោទដែលបានស្រុះស្រួលដោយផ្ទាល់ ជាមួយក្រុមសម្របសម្រួលបណ្តឹងតាមតំបន់ឈ្វងសមុទ្រ ឬ តុលាការរបស់រដ្ឋដែលដើមចោទត្រូវបានតំណាងដោយក្រុមប្រឹក្សាដែលបានចូលរួមក្នុងការស្វែងរកឯកសារក្នុងបណ្តឹងសម្ហភាព (MDL)។ ការលើកលែងពីសេចក្តីតម្រូវលើការកាត់ប្រាក់

(អវត្តមានសាលក្រមស្ពាពរឬសាលក្រមផ្សេងទៀតដែលតម្រូវឲ្យចុងចម្លើយបង់កម្រៃមួយភាគឬទាំងអស់លើសេវាមេធាវី) គួរតែត្រូវបម្រុងទុកឬ "កាត់ពី" មូលនិធិសាលក្រម មូលនិធិដោះស្រាយបណ្តឹង ឬមូលនិធិចំណាយផ្សេងៗទៅដើមចោទ ដើម្បីទបើស្កាត់សកម្មភាពនានារបស់តុលាការនាពេលអនាគត។ ទោះបីដើមចោទអាចរក្សាសិទ្ធិក្នុងការស្វែងរកផលប្រយោជន៍និង/ឬកម្រៃសេវាមេធាវីផ្សេងទៀតយោងតាមបទប្បញ្ញត្តិអំពីការអនុវត្តការផ្ទេរកម្រៃសេវា គ្មានអ្វីនៅក្នុងសាលក្រម*នេះ* អាច*តម្រូវឲ្យ*ចុងចម្លើយមួយបង់ប្រាក់កម្រៃ ដើម្បីផលប្រយោជន៍រួមរបស់ដើមចោទនិង/ឬកម្រៃសេវាមេធាវីឡើយ។

[5] ក្នុងករណីដែលចុងចម្លើយមិនយល់ព្រមបង់ប្រាក់តាមការកំណត់ភាគរយលើការដោះស្រាយបណ្តឹង, សូមមើលកំណត់បង្ហាញលេខ 4, តុលាការមានបំណងថារាល់ដើមចោទដែលត្រូវបានតំណាងដោយក្រុមប្រឹក្សា ការកាត់ប្រាក់ត្រូវដកប្រាក់ពីកម្រៃសេវាមេធាវីជាជាងយកពីការជួសជុលចំណងសមាមាត្ររបស់ អតិថិជន។

គឺក្រុមប្រឹក្សាតុលាការរបស់រដ្ឋដែលមាន ឬមិនមានបណ្តឹងនៅក្នុងបណ្តឹងសមូហភាពនេះ និងដែលមិនបាន ចូលរួមក្នុងការស្វែងរកឯកសារក្នុងបណ្តឹងសមូហភាព។ គ្មានអ្វីនៅក្នុងសាលក្រមនេះមានបំណងអនុវត្តការ ដោះស្រាយបណ្តឹង ការចេញសាលក្រម ឬការចំណាយផ្សេងៗរវាង ឬក្នុងចំណោម BP, Transocean, Cameron, Halliburton, Weatherford, M-I, Anadarko, MOEX និង/ឬ ចុងចម្លើយដទៃទៀត ឬអ្នកធានាណាមួយរបស់ពួកគាត់ទេ។

ចុងចម្លើយត្រូវដេញថ្លៃប្រាក់កក់ទាំងនោះទៅក្រឡាបញ្ជីរបស់តុលាការ អាសយដ្ឋាន 500 Poydras Street, Room C-151, New Orleans, Louisiana 70130 សម្រាប់ប្រាក់កក់នៅក្នុង បណ្តឹងសមូហភាព MDL No. 2179 Accountand Reserve for Common Benefit Litigation Expenses (“MDL No. 2179 Reserve Account”)។

រាល់ប្រាក់កក់ទាំងអស់ទៅ MDL No. 2179 Reserve Account ត្រូវភ្ជាប់ជាមួយនូវព័ត៌មាន ដែលអាចកំណត់អំពីភាគី និងមេធាវីដែលបានបង់ប្រាក់កក់។ ចុងចម្លើយដែលមានតំណាងបង់ប្រាក់ បរិមាណប្រាក់ដោះស្រាយបណ្តឹង ការចេញសាលក្រមឬការចំណាយផ្សេងៗ និងដើមចោទ អ្នកប្តឹង ឬសមាជិកក្រុមដែលការដោះស្រាយបណ្តឹង ការចេញសាលក្រមឬការចំណាយផ្សេងៗត្រូវបានចំណាយ។

ព័ត៌មានទាំងនោះត្រូវតែរក្សាជាការសំងាត់ ហើយការមើលព័តមានទាំងនោះត្រូវមានការកំណត់ ដោយយោងតាមនីតិវិធីដែលបានកំណត់នៅក្នុងបទបញ្ជារបស់សវនការបឋម លេខ 9។ តាមរយៈនេះ Phil Garrett CPA ត្រូវតាមដានព័ត៌មានទាំងនោះ និងធ្វើរបាយការណ៍តាមកាលកំណត់ទៅតុលាការ និង ដើមចោទ Co-Liaison។ រាល់ការបង្ហាញព័ត៌មានទាំងនោះតម្រូវឲ្យមានបទបញ្ជាអនុញ្ញាតពីតុលាការនេះ។

គ្មានភាគី ឬមេធាវីណាមួយមានសិទ្ធិតម្កល់អ្វីឬរក្សាមូលនិធិនៅក្នុងគណនីរបស់តុលាការនេះ ហើយ មូលនិធិទាំងនេះមិនអាចបង្កើតឲ្យមានការបែងចែកទ្រព្យសម្បត្តិរបស់ភាគីណាមួយ ឬមេធាវីណាមួយឡើយ ឬជាកម្មវត្ថុនៃការទាមទារបំណុលឬការជំពាក់បំណុលរបស់ភាគីឬមេធាវីណាមួយឡើយ។ មូលនិធិទាំងនោះ មិនអាចត្រូវបានចាត់ចែង ចំណាយឬបែងចែកឡើយ លើកលែងតែមានបទបញ្ជាអនុញ្ញាតពីតុលាការនេះ។ រាល់សំណួរនានាដែលទាក់ទងនឹងនីតិវិធីនៃការតម្កល់ប្រាក់ប្រដាប់ក្តីនៅក្រឡាបញ្ជីរបស់តុលាការ សូមទាក់ទងផ្ទាល់ជាមួយលោក Kim Lange ផ្នែកហិរញ្ញវត្ថុ ក្រឡាបញ្ជីតុលាការ តាមទូរស័ព្ទលេខ 504-

589-7786 ឬតាមអ៊ីម៉ែល kim_lange@laed.uscourts.gov ។

រាល់សំណួរទាក់ទងនឹងទ្រព្យសម្បត្តិដែលត្រូវតម្កល់ សូមទាក់ទងផ្ទាល់ជាមួយ Philip Garrett, CPA, Garrett and Company CPA's, 117Fairgrounds Boulevard, Bush, Louisiana 70431, ទូរស័ព្ទលេខ 985-635-1500 និងអ៊ីម៉ែល pgarrett@garrettco.com។

**បានចុះហត្ថលេខានៅទីក្រុង ញូ អរលៀន នៃរដ្ឋល្វីស៊ាណា** ថ្ងៃទី28 ខែធ្នូ ឆ្នាំ2011

(ហត្ថលេខា)

ចៅក្រមនៃតុលាការជំបូងរបស់សហរដ្ឋអាមេរិក